**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ: ៧៣ អយក.សណន**

# សេចក្តីណែនាំ
## ស្តីពី
## ការចាប់ផ្តើមវិស្សមកាលតូច និងការឈប់សម្រាកមុនកាលកំណត់ សម្រាប់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈនិងឯកជន នៅទូទាំងប្រទេស

ផ្អែកតាមរបាយការណ៍ស្ថានភាពរាតត្បាតនៃវីរុសកូវីដ១៩ របស់អង្គការសុខភាពពិភពលោក ព្រមទាំងការរកឃើញជាបន្តបន្ទាប់នូវវិជ្ជមានវីរុសកូវីដ១៩ លើជនជាតិខ្មែរ និងជនបរទេស ដែលធ្វើដំណើរចូលមកព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានវិធានការបង្ការ និងទប់ស្កាត់ជាបន្ទាន់ និងតាមការណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡាសូមណែនាំដល់គ្រឹះស្ថានសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈនិងឯកជននៅទូទាំងប្រទេស ដូចតទៅ៖

**១. គ្រឹះស្ថានសិក្សាចំណេះទូទៅ (បឋមសិក្សា ដល់មធ្យមសិក្សាទុតិយភូមិ) និងមត្តេយ្យសិក្សាគ្រប់កម្រិត គ្រប់ប្រភេទ ទាំងសាធារណៈ និងឯកជន**

- ចាប់អនុវត្តវិស្សមកាលតូចមុនកាលកំណត់ ចាប់ពីថ្ងៃទទួលបានសេចក្តីណែនាំនេះ រហូតដល់មានការជូនដំណឹងជាថ្មី
- សម្រាប់សាលារៀនដែលមិនទាន់បានបញ្ចប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សក្នុងឆមាសទី១ តម្រូវឱ្យយកលទ្ធផលសិក្សាជាមធ្យមភាគនៃពិន្ទុប្រចាំខែ ចាប់ពីខែធ្នូ ឆ្នាំ២០១៩ រហូតដល់ខែកុម្ភៈ ឆ្នាំ២០២០ ជាមធ្យមភាគពិន្ទុប្រចាំឆមាសទី១។

**២. គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាទាំងសាធារណៈនិងឯកជន**

- អនុញ្ញាតឱ្យគរុសិស្ស គរុនិស្សិត និងនិស្សិតឈប់សម្រាកចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ រហូតដល់មានការជូនដំណឹងជាថ្មី
- ត្រូវប្រមូលព័ត៌មាននូវរាល់ការធ្វើដំណើរ កម្មវិធីទស្សនកិច្ច កម្មសិក្សារបស់គរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកអប់រំ ទៅកាន់ប្រទេសដែលមានផ្ទុះករណីជំងឺកូវីដ-១៩ ក្នុងអំឡុងពេល១៤ថ្ងៃ មុនថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០
- ករណីដែលគរុសិស្ស គរុនិស្សិត និស្សិត និងបុគ្គលិកសិក្សាដែលមានប្រវត្តិធ្វើដំណើរទៅកាន់ប្រទេសទាំងនេះ ហើយមានការសង្ស័យចំពោះស្ថានភាពសុខភាពផ្ទាល់ខ្លួន ឬមានរោគសញ្ញាស្រដៀងនឹងជំងឺកូវីដ-១៩ ត្រូវទូរស័ព្ទជាបន្ទាន់ទៅលេខ **១១៥** ដើម្បីពិគ្រោះយោបល់ និងផ្តល់ព័ត៌មានមកកាន់ជនបង្គោលរបស់គ្រឹះស្ថានសិក្សា ដើម្បីរាយការណ៍មកក្រសួងអប់រំ យុវជន និងកីឡា។

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៤៧ /២១៧ ២៥៣ /៤២៦ ៥៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / ...@camnet.com.kh គេហទំព័រ: www.moeys.gov.kh

**៣. មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

- ចាត់តាំង **ក្រុមការងារទប់ស្កាត់ការីករាលដាលនៃវីរុសកូវីដ១៩** ដើម្បីតាមដាន និងរាយការណ៍ហេតុការណ៍ ដែលអាចកើតមានឡើងចំពោះបុគ្គលិកអប់រំ និងសិស្សានុសិស្ស និងផ្តល់ព័ត៌មានដល់ក្រសួងអប់រំ យុវជន និងកីឡារៀងរាល់ថ្ងៃ តាមប្រព័ន្ធទំនាក់ទំនងដែលមានស្រាប់ ក្នុងករណីមានការសង្ស័យណាមួយ។

**៤. មាតាបិតា អ្នកអាណាព្យាបាល**

- ក្រសួងសូមលើកទឹកចិត្តដល់មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប ត្រូវជំរុញឱ្យកូនចៅធ្វើស្វ័យសិក្សានៅតាមផ្ទះ និងត្រូវមើលថែកូនចៅ និងចៀសវាងទៅកន្លែងមួយចំនួន ដែលប្រឈមនឹងការឆ្លងខ្ពស់ ដូចជា៖ កន្លែងហែលទឹកសាធារណៈ កន្លែងហាត់ប្រាណ សួនកុមារ និងកន្លែងផ្សេងទៀតដែលមានហានិភ័យខ្ពស់ក្នុងការឆ្លងវីរុសកូវីដ១៩ ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត ត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់គ្រប់ការិយាល័យអប់រំ យុវជន និងកីឡានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ កម្រងសាលារៀន សាលារៀន និងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូគ្រប់កម្រិត។ ដោយឡែក គណៈគ្រប់គ្រងសាលារៀនគ្រប់កម្រិត គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ បុគ្គលិកអប់រំ មាតាបិតា អ្នកអាណាព្យាបាលគ្រប់រូប សូមចូលរួមសហការអនុវត្តដោយស្មារតីទទួលខុសត្រូវខ្ពស់ និងសូមមេត្តាតាមដានជាប្រចាំនូវការផ្សព្វផ្សាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសុខាភិបាល។ ៸

ថ្ងៃ ច័ន្ទ ៧រោច ខែ ផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមីនា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- គ្រប់សាលារាជធានី ខេត្ត
- គ្រប់អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
  **"ដើម្បីជ្រាបជាព័ត៌មាន"**
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
  **"ដើម្បីអនុវត្ត"**
- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋានសុខភាពសិក្សា